**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible] ប្រកាសព័ត៌មាន

*ថ្ងៃព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការដាក់ឱ្យអនុវត្ត
## ប្រកាសស្តីពី ដើមទុនបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ
## និង
## ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ធនាគារជាតិនៃកម្ពុជា មានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងសាធារណជនទូទៅ ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជា បានសម្រេចដាក់ឱ្យអនុវត្តប្រកាសចំនួន ២ គឺ ប្រកាសស្តីពី ដើមទុនបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ប្រកាសទាំង ២ នេះ គឺជាផ្នែកមួយនៃក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនឬសាធនភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ប្រកាសទាំង ២ នេះ ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារអន្តរជាតិ និងគិតគូរច្បាស់លាស់ពីបរិបទ ការវិវឌ្ឍ និងទស្សនៈអនាគតនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងកត្តាច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ប្រកាសស្តីពី ដើមទុនបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មានគោលបំណងពង្រឹងដើមទុននិងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្នុងការទប់ទល់នឹងហានិភ័យផ្សេងៗ ជាពិសេស គឺហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យទីផ្សារ សំដៅការពារអ្នកដាក់ប្រាក់បញ្ញើ អ្នកវិនិយោគ និងរក្សាស្ថិរភាពអាជីវកម្មរបស់គ្រឹះស្ថាន ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល។ ប្រកាសនេះ ក៏ឆ្លុះបង្ហាញពីការត្រៀមលក្ខណៈជាស្រេចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុទៅអនាគត តាមរយៈការកំណត់ជាមុននូវលក្ខខណ្ឌនៃការទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងដើមទុនថ្នាក់ទី១ និង ថ្នាក់ទី២ របស់គ្រឹះស្ថាន។ ការអនុវត្តតាមវិធាននិងស្តង់ដារអន្តរជាតិដែលកំណត់ក្នុងប្រកាសនេះក៏នឹងជួយលើកកម្ពស់កេរ្តិ៍ឈ្មោះប្រព័ន្ធធនាគារកម្ពុជាទាំងមូល និងបង្កើនជំនឿទុកចិត្តដល់វិនិយោគិន និងស្ថាប័នផ្តល់កម្ចីនានា ជាពិសេស ស្ថាប័នផ្តល់កម្ចីពីបរទេស។

ទន្ទឹមនេះ ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក៏ត្រូវបានរៀបចំឡើងក្នុងគោលបំណងដាក់ចេញនូវវិធាននៃការថ្លឹងហានិភ័យឥណទានយ៉ាងទូលំទូលាយ ដែលការថ្លឹងនេះមានកម្រិតខុសៗគ្នាផ្អែកលើប្រភេទឥណទាន និង



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អ្នកខ្ចីឬសមភាគី និងឆ្លុះបង្ហាញពីកម្រិតហានិភ័យដែលគ្រឹះស្ថានអាចប្រឈមជាក់ស្តែង សំដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ។ ទន្ទឹមនឹងការដាក់វិធានប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជាក៏ថ្លឹងថ្លែង និងគិតគូរយ៉ាងម៉ត់ចត់ដល់ការជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ព្រមទាំងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជំរុញការអនុវត្តគោលនយោបាយពាក់ព័ន្ធ ក្នុងនោះមានការយកចិត្តទុកដាក់ជាពិសេសចំពោះ៖

- ការគាំទ្រដល់ការបោះផ្សាយមូលបត្ររដ្ឋតាមរយៈការថ្លឹងហានិភ័យសូន្យភាគរយ ដើម្បីជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមវិនិយោគលើមូលបត្ររដ្ឋ និងលើកកម្ពស់លទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលទុនដើម្បីអភិវឌ្ឍប្រទេសជាតិ
- ការគាំទ្រនិងលើកទឹកចិត្តដល់ការផ្តល់ឥណទានទៅសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលមានការចុះបញ្ជីត្រឹមត្រូវ និងមានរបាយការណ៍ហិរញ្ញវត្ថុសមស្រប តាមរយៈការថ្លឹងហានិភ័យត្រឹមតែ ៧៥% ដើម្បីឱ្យសហគ្រាសទាំងនោះអាចទទួលបានឥណទានក្នុងអត្រាការប្រាក់សមរម្យពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកពង្រឹងការអនុវត្តវិធានការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារចំពោះសហគ្រាសទាំងនោះផងដែរ តាមរយៈយន្តការលើកទឹកចិត្តដល់សហគ្រាសដែលនៅក្រៅប្រព័ន្ធឱ្យចូលមកក្នុងប្រព័ន្ធផ្លូវការ
- ការគាំទ្រដល់យន្តការធានាឥណទានដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជាសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដោយការថ្លឹងហានិភ័យសូន្យភាគរយចំពោះចំណែកឥណទានដែលត្រូវបានធានា ដើម្បីសម្រួលឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យមទទួលបានប្រភពទុនកាន់តែច្រើនជាងមុន
- ការគាំទ្រចំពោះវិស័យកសិកម្ម វិស័យអប់រំ និងសុខុមាលភាពប្រជាពលរដ្ឋ តាមរយៈការបន្ធូរបន្ថយការថ្លឹងហានិភ័យក្នុងកម្រិត ៨៥% ចំពោះឥណទានក្នុងទំហំសមស្របដែលផ្តល់ឱ្យរូបវន្តបុគ្គល
- ការគាំទ្រដល់ការទិញលំនៅឋានសម្រាប់គោលបំណងស្នាក់នៅ តាមរយៈការបន្ធូរបន្ថយការថ្លឹងហានិភ័យឥណទាន
- ការដាក់ឱ្យអនុវត្តអនុបាតឥណទានធៀបនឹងតម្លៃអចលនទ្រព្យ (LTV) តឹងរ៉ឹងសម្រាប់ឥណទានចំពោះវិស័យអចលនទ្រព្យ សំដៅលើកកម្ពស់ការអនុវត្តស្តង់ដារអន្តរជាតិ រក្សាស្ថិរភាពហិរញ្ញវត្ថុ និងលើកទឹកចិត្តដល់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យឱ្យចុះបញ្ជីជានីតិបុគ្គល ដែលការណ៍នេះនឹងរួមចំណែកពង្រឹងការអនុវត្តវិធានការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ
- ការគាំទ្រនិងលើកទឹកចិត្តដល់ហិរញ្ញប្បទានបៃតង តាមរយៈការបន្ធូរបន្ថយការថ្លឹងហានិភ័យត្រឹមតែ ៨០% ក្នុងអំឡុងពេលគម្រោងកំពុងប្រតិបត្តិការ និង
- ការលើកទឹកចិត្តចំពោះការវិនិយោគលើប្រព័ន្ធព័ត៌មានវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជា សង្ឃឹមយ៉ាងមុតមាំថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលព្រាកាសរញ្ញេ និងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃប្រកាសទាំង ២ នេះ យ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាព។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA